ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម

លេខ ០០៤២០/២៣ ន.គ.ស/សា.ន.ល.

ថ្ងៃសុក្រ ៤កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង

## ស្តីពី

## ការមិនបញ្ចប់នៃការទទួលរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២២ សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ មិនរងសវនកម្មឯករាជ្យ មកនិយ័តករគណនេយ្យនិងសវនកម្ម

យោងតាមសេចក្តីជូនដំណឹងលេខ ០០១៥/២៣ ន.គ.ស/ស.ជ.ណ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៣ ស្តីពីការផ្តល់ពេលវេលាបន្ថែមក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២ សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ មិនរងសវនកម្មឯករាជ្យ មកនិយ័តករគណនេយ្យនិងសវនកម្ម តាមប្រព័ន្ធអនឡាញ (E-Filing System) កាលបរិច្ឆេទដាក់បញ្ជូននឹងត្រូវផុតកំណត់នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ ខាងមុខនេះ។ ប៉ុន្តែ ដោយមានការស្នើសុំពេលវេលាបន្ថែមពីម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ **និយ័តករគណនេយ្យនិងសវនកម្ម** (**ន.គ.ស.**) នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** សម្រេចផ្តល់ជូនសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ មិនរងសវនកម្មឯករាជ្យ នូវពេលវេលាបន្ថែមចំនួន ***៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទី១៦ ខែឧសភា ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣*** ដើម្បីដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២ របស់ខ្លួនមក **ន.គ.ស.** តាមប្រព័ន្ធអនឡាញ (E-Filing System)។

<u>ការខកខានមិនបានដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២ មក **ន.គ.ស.** តាមកាលបរិច្ឆេទកំណត់ខាងលើ ជាកម្មវត្ថុនៃការពិន័យអន្តរការណ៍ ដូចបានកំណត់នៅក្នុងអនុក្រឹត្យលេខ៧៩ អនក្រ.បក. ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម។</u>

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ មិនរងសវនកម្មឯករាជ្យ ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**អគ្គនាយក**

**ប៊ូ ថារិន**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់និយ័តករគណនេយ្យនិងសវនកម្ម

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ ០២៣ - ៨៨ ២៨២ ១១១
Phone: 023 882 111